ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

# របាយការណ៍កិច្ចប្រជុំ

# ក្រុមប្រឹក្សាបច្ចេកទេសអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

**១. ថ្ងៃ ខែ ឆ្នាំ ៖** ថ្ងៃសុក្រ១០រោច ខែភទ្របទ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២៤។

**២. ទីកន្លែង ៖** អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងតាមប្រព័ន្ធនិម្មិត(Zoom)។

**៣. ប្រធាន និងសមាសភាពចូលរួម ៖**

៣-១-ប្រធានអង្គប្រជុំ **ឯកឧត្តមបណ្ឌិត ឈឹម យិនដារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

៣-២- សមាសភាពចូលរួមមាន សមាជិក សមាជិកាថ្នាក់បច្ចេកទេសអន្តរក្រសួង ស្ថាប័ន រាជធានី ខេត្ត អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធ ដែលមានសមាជិកចូលរួមនៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ចំនួន៣០រូប និងតាមប្រព័ន្ធនិម្មិត(Zoom) ចំនួន៣៨រូប សរុបចំនួន៦៨រូប។

**៤. របៀបវារៈ៖**

៤.១ មតិស្វាគមន៍ និងគោលបំណងរបស់ **ឯកឧត្តមបណ្ឌិត ឈឹម យិនដារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងជាប្រធានក្រុមប្រឹក្សាបច្ចេកទេស។

៤.២ បទបង្ហាញស្តីពី "ស្ថានភាពមេរោគអេដស៍ និងសមិទ្ធផលសំខាន់ៗក្នុងការអនុវត្តកម្មវិធីបង្ការការចម្លងមេរោគអេដស៍ក្នុងចំណោមប្រជាជនចំនុច" បង្ហាញដោយ **លោកវេជ្ជបណ្ឌិត វ៉ិត ស្រេង** សមាជិកក្រុមប្រឹក្សាបច្ចេកទេស និងជាប្រធានគម្រោងបង្ការអេដស៍ភូមិភាគឧត្តរ នៃអង្គការ RHAC។

៤.៣ មតិបូកសរុប និងបិទកម្មវិធីដោយ **ឯកឧត្តមបណ្ឌិត ឈឹម យិនដារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

**៥. សកម្មភាព និងលទ្ធផល ៖**

ជាកិច្ចចាប់ផ្តើម **ឯកឧត្តមបណ្ឌិត ឈឹម យិនដារ៉េត** អគ្គលេខាធិការនៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានថ្លែងនូវមតិស្វាគមន៍ដល់ក្រុមការងារ និងអង្គប្រជុំ ដោយបានថ្លែងនូវការកោតសរសើរក្រុមប្រឹក្សាបច្ចេកទេស ដែលបានប្រឹងប្រែងក្នុងការអនុវត្តការឆ្លើយតបនឹងមេរោគអេដស៍កន្លងមក ជាពិសេសការជំរុញការងារបង្ការលើក្រុមប្រជាជនគន្លឹះដែលបង្កឱ្យអត្រាប្រេវ៉ាឡង់មេរោគអេដស៍ នៅកម្ពុជាបានធ្លាក់ចុះជាបន្តបន្ទាប់មកនៅត្រឹមតែ ០,៥% នៅឆ្នាំ២០២៣។ លទ្ធផលប្រសើរនេះ បានមកអាស្រ័យដោយមានការយកចិត្តទុកដាក់ពីថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដឹកនាំដោយ **ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍** ដោយមានការគាំទ្រពី **អតីតប្រមុខរាជរដ្ឋាភិបាល សម្តេចតេជោ ហ៊ុន សែន** ដែលបានអំពាវនាវជាចលនាជាតិតែមួយក្នុងការឆ្លើយតបនឹងមេរោគអេដស៍ និង

គិតគូរប្រកបដោយគតិបណ្ឌិតរបស់**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**។ ឯកឧត្តមក៏បានជម្រាបក្រុមការងារអំពីការវិវត្តន៍ថ្មីនៃការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ដូចជា៖ ការផ្សព្វផ្សាយនូវផែនការយុទ្ធសាស្ត្រជាតិលើកទី៦ ឆ្នាំ២០២៣-២០២៨ និងការប្រកាសលទ្ធផលការវិភាគចំណាយជាតិឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍លើកទី៧ ឆ្នាំ២០២០-២០២២។

ជាបន្ត **ឯកឧត្តមបណ្ឌិត** ក៏បានបញ្ជាក់ពីការបង្កើតនូវក្រុមការងារស្នូលយុទ្ធសាស្ត្រទាំង៥ សម្រាប់ដឹកនាំការអនុវត្តនូវផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍លើកទី៦ ឆ្នាំ២០២៣-២០២៨ ដើម្បីឈានទៅសម្រេចបានគោលដៅជាតិ ៩៥-៩៥-៩៥ តាមកាលកំណត់ និងបន្តនូវនិរន្តភាពក្នុងឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍។ យុទ្ធសាស្ត្រទាំង៥ រួមមាន៖

១- ផ្តល់ការបង្ការ ការថែទាំ ព្យាបាល និងគាំទ្រយ៉ាងទូលំទូលាយតាមរយៈ វិធីសាស្ត្រពហុវិស័យ។

២- ធ្វើសមាហរណកម្មសកម្មភាពឆ្លើយតបមេរោគអេដស៍ទៅក្នុងប្រព័ន្ធសុខាភិបាលសង្គមពាក់ព័ន្ធនឹងអង្គភាពសម្របសម្រួលថ្នាក់ជាតិ។

៣- កសាងសមត្ថភាពស្ថាប័ន សហគមន៍ និងបុគ្គល ដើម្បីពង្រឹងការឆ្លើយតបដោយសហគមន៍ និងកែលម្អការធ្វើសមាហរណកម្មឆ្លើយតបនឹងមេរោគអេដស៍ក្នុងវិស័យសុខាភិបាល និងវិស័យមិនមែនសុខាភិបាល។

៤- ធានាចីរភាពសមិទ្ធផលជាតិនៃការឆ្លើយតបនឹងមេរោគអេដស៍ ដោយអភិបាលកិច្ចសម្របសម្រួល និងត្រួតពិនិត្យ។

៥- ត្រួតពិនិត្យ តាមដាន វាយតម្លៃវឌ្ឍនភាពនៃការអនុវត្តយុទ្ធសាស្ត្រ។

ជាបន្ត **ឯកឧត្តមបណ្ឌិត** បានអនុញ្ញាតជូន**លោកវេជ្ជបណ្ឌិត រ៉ុត ស្រេង** សមាជិកក្រុមប្រឹក្សាបច្ចេកទេស និងជាប្រធានគម្រោងបង្ការអេដស៍ភូមិភាគឧត្តរនៃអង្គការ RHAC ធ្វើបទបង្ហាញដែលផ្តោតលើស្ថានភាពមេរោគអេដស៍ និងសមិទ្ធផលសំខាន់ៗ ក្នុងការអនុវត្តកម្មវិធីបង្ការការចម្លងមេរោគអេដស៍ក្នុងចំណោមប្រជាជនគន្លឹះគោលដៅ ដោយលោកបានបង្ហាញពី៖

១- ស្ថានភាពមេរោគអេដស៍ ក្នុងចំណោមក្រុមប្រជាជនគោលដៅ និងក្រុមផ្សេងៗទៀត

២- គោលបំណង សូចនាករ និងគោលដៅចំណុច។

៣- សកម្មភាព និង សមិទ្ធផលចម្បងៗ នៃការឆ្លើយតបនឹងការបង្ការការចម្លងមេរោគអេដស៍ ឆ្នាំ ២០២២ ដល់ឆមាសទី១ឆ្នាំ ២០២៤។

៤- បញ្ហាប្រឈម និងដំណោះស្រាយ។

៥-ទិសដៅ និងផែនការអនុវត្តបន្ត។

លោកបានបង្ហាញពីគោលបំណងនៃគម្រោង គឺការបង្កើនការស្វែងរកករណីវិជ្ជមានថ្មី ក្នុងចំណោមក្រុមប្រឈមខ្ពស់ ( នារីធ្វើការនៅកន្លែងសេវាកម្សាន្ត បុរសស្រឡាញ់ភេទដូចគ្នា និងអ្នកប្លែងភេទ ) តាមអន្តរាគមន៍ថ្មីៗ និងពង្រីកតំបន់គ្របដណ្តប់ និងជំរុញការប្រើថ្នាំប្រើព និងស្រោមអនាម័យ ដែលមានតំបន់គ្របដណ្តប់ និងអ្នកទទួលផលនៃគម្រោងរ៉ាក់នេះដែលគ្របដណ្តប់១៣ខេត្តនៅភាគខាងលិច និងខាងជើងនៃប្រទេស (កំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង ប៉ៃលិន បន្ទាយមានជ័យ ឧត្តរមានជ័យ សៀមរាប កំពង់ធំ មណ្ឌលគិរី ស្ទឹងត្រែង ក្រចេះ ព្រះវិហារ និងរតនគិរី) និងមានក្រុមគោលដៅ ៤៥.០០៣នាក់ មានដូចជា

ក្រុមបុរសស្រឡាញ់បុរស ២៣.៩២០នាក់ ស្ត្រីធ្វើការនៅសេវាកម្សាន្ត ១៧.២១៦នាក់ និងអ្នកប្លែងភេទ ៣.៨៦៧នាក់។ លោកវេជ្ជបណ្ឌិត ក៏បានបង្ហាញពីផលវិបាក និងទិសដៅ ព្រមទាំងផែនការអនុវត្តបន្ត។

ជាបន្ត **ឯកឧត្តមបណ្ឌិត** បានអនុញ្ញាតឱ្យមានកិច្ចពិភាក្សា និងផ្តល់យោបល់យ៉ាងផុលផុស និងទទួលយកនូវសំណូមពរនានា ដើម្បីពិនិត្យសម្រេច។

ជាចុងក្រោយ **ឯកឧត្តមបណ្ឌិត** បានផ្តល់នូវមតិ និងអនុសាសន៍ដល់កិច្ចប្រជុំដូចខាងក្រោម៖

- ក្រុមប្រឹក្សាបច្ចេកទេសយល់ឱ្យកាន់តែច្បាស់ពីទិន្នន័យបែបវិទ្យាសាស្ត្រនានា ជាភស្តុតាងក្នុងការរៀបចំផែនការសកម្មភាពឆ្លើយតបនឹងមេរោគអេដស៍។
- សមាជិកក្រុមបច្ចេកទេសដែលប្រតិបត្តិករ ស្វែងយល់ឱ្យបានកាន់តែស៊ីជម្រៅទៅលើកត្តាដែលធ្វើឱ្យមានការឆ្លងថ្មីកើនឡើង ជាពិសេសក្នុងចំណោមក្រុមប្រជាជនគន្លឹះ។
- ស្វែងយល់ពីគោលដៅនៃការប្រឈមថ្មី និងស្វែងរកដំណោះស្រាយឱ្យបានសមស្រប ក្នុងការកំណត់ជាអាទិភាព និងសកម្មភាពក្នុងការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ឱ្យកាន់តែមានប្រសិទ្ធិភាព និងស័ក្តិសិទ្ធិភាព ដើម្បីឈានទៅសម្រេចគោលបំណងនៃគោលនយោបាយបញ្ចប់អេដស៍ និងសម្រេចបាននូវគោលដៅនៃផែនការយុទ្ធសាស្ត្រជាតិ។
- ធានានូវនិរន្តភាពនៃការឆ្លើយតបនឹងមេរោគអេដស៍ឱ្យកាន់ប្រសើរ។

កិច្ចប្រជុំបានដំណើរការទៅតាមរបៀបវារៈដែលបានគ្រោងទុក។ ជាទីបញ្ចប់នៃកិច្ចប្រជុំ **ឯកឧត្តមបណ្ឌិត** បានជូនពរដល់សមាជិកអង្គប្រជុំ ឱ្យជួបប្រទះតែនឹងពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

ថ្ងៃសុក្រ ១០រោច ខែភទ្របទ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២៤

បានពិនិត្យត្រឹមត្រូវ

អ្នកធ្វើរបាយការណ៍

បានឃើញ និងឯកភាព

ប្រធានអង្គប្រជុំ

ប្រធាននាយកដ្ឋានទាក់ទង និងចលនាប្រភពធនធាន

**បណ្ឌិត ឈឹម ឃិនដារ៉េត**

**វេជ្ជ. ហួត សេរីវុធ**

**ស៊ុំ ផល្លា**